**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- យោងអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើ មាត្រា៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងសេចក្តីជូនដំណឹងលេខ ២៦៨ សជណ.សរ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីលទ្ធផលនៃសម័យប្រជុំច្រកចេញ-ចូលតែមួយនៃគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ** ( **PHNOM PENH SEZ**) ដែលមានទីតាំងស្ថិតនៅចន្លោះឃុំភ្លើងឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងឃុំកន្ទោក-ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ** មានទំហំ បីរយហាសិបហិកតា និងដប់ម៉ែត្រក្រឡា ដូចមានប្លង់ទីតាំងព្រំប្រទល់ ភូមិសាស្ត្រ ក្នុងឧបសម្ព័ន្ធដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជន ស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទបញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ-រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ-អភិបាលរាជធានីភ្នំពេញ-អភិបាលខេត្តកណ្តាល និងក្រុមហ៊ុន ភ្នំពេញអេសអ៊ី ហ្សិតខូអិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស

សុខ ចិន្តា

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៥ ដើម្បីសហការអនុវត្ត
- ឯកសារ-កាលប្បវត្តិ




| Points | Northing | Easting | Points | Northing | Easting |
|---|---|---|---|---|---|
| 001 | 1273556.848 | 475943.224 | 079 | 1269220.350 | 476028.630 |
| 002 | 1273516.563 | 475950.442 | 080 | 1269345.098 | 476019.048 |
| 003 | 1273509.952 | 475944.971 | 081 | 1269369.066 | 476016.084 |
| 004 | 1273506.293 | 475945.255 | 082 | 1269639.137 | 476016.881 |
| 005 | 1273491.694 | 475909.511 | 083 | 1269662.672 | 476010.923 |
| 006 | 1273486.459 | 475933.735 | 084 | 1269684.578 | 476003.127 |
| 007 | 1273466.280 | 475935.428 | 085 | 1270182.343 | 475977.414 |
| 008 | 1273465.048 | 475922.146 | 086 | 1270453.610 | 475901.600 |
| 009 | 1273459.393 | 475917.744 | 087 | 1270602.941 | 475939.012 |
| 010 | 1273409.691 | 475941.037 | 088 | 1269171.550 | 476104.690 |
| 011 | 1273345.697 | 475966.598 | 089 | 1269188.500 | 476614.260 |
| 012 | 1273269.203 | 475977.565 | 090 | 1269243.970 | 476632.020 |
| 013 | 1273204.309 | 475995.921 | 091 | 1269259.380 | 476744.230 |
| 014 | 1273188.844 | 476133.103 | 092 | 1269258.430 | 476799.200 |
| 015 | 1272997.839 | 476134.330 | 093 | 1268326.450 | 476569.900 |
| 016 | 1272856.045 | 476147.047 | 094 | 1268325.750 | 476047.210 |
| 017 | 1272509.705 | 476162.220 | 095 | 1268909.538 | 476059.459 |
| 018 | 1272433.960 | 476159.280 | 096 | 1268924.059 | 476073.979 |
| 019 | 1272360.540 | 475546.620 | 097 | 1269023.912 | 476078.381 |
| 020 | 1272497.651 | 475523.496 | 098 | 1269170.692 | 476070.398 |
| 021 | 1272580.952 | 475671.601 | 099 | 1268314.440 | 476567.250 |
| 022 | 1272584.368 | 475748.986 | 100 | 1268075.767 | 476508.297 |
| 023 | 1272800.832 | 475786.532 | 101 | 1268077.002 | 476485.086 |
| 024 | 1272939.155 | 475803.652 | 102 | 1267963.672 | 476481.825 |
| 025 | 1272957.551 | 475834.834 | 103 | 1267793.060 | 476440.480 |
| 026 | 1273007.735 | 475846.934 | 104 | 1267796.033 | 476412.214 |
| 027 | 1273154.487 | 475858.313 | 105 | 1267731.200 | 476408.940 |
| 028 | 1273205.514 | 475869.051 | 106 | 1267725.160 | 476312.010 |
| 029 | 1273327.467 | 475883.795 | 107 | 1267743.605 | 476314.535 |
| 030 | 1273349.667 | 475886.651 | 108 | 1267798.391 | 476321.521 |
| 031 | 1273393.395 | 475880.869 | 109 | 1267866.010 | 476355.900 |
| 032 | 1273394.169 | 475845.977 | 110 | 1267997.740 | 476360.440 |
| 033 | 1273462.590 | 475825.120 | 111 | 1268000.615 | 476040.102 |
| 034 | 1273509.889 | 475804.770 | 112 | 1268313.750 | 476046.920 |
| 035 | 1272427.990 | 476159.800 | 113 | 1267703.381 | 476416.868 |
| 036 | 1272343.137 | 476156.574 | 114 | 1267291.198 | 476314.913 |
| 037 | 1271910.640 | 476089.540 | 115 | 1266904.179 | 476219.822 |
| 038 | 1271903.119 | 476165.976 | 116 | 1266471.680 | 476112.680 |
| 039 | 1271905.080 | 476250.364 | 117 | 1266521.140 | 475919.070 |
| 040 | 1271695.037 | 476264.471 | 118 | 1266577.424 | 475936.625 |
| 041 | 1271466.012 | 476272.124 | 119 | 1266590.252 | 475917.341 |
| 042 | 1271122.095 | 476292.429 | 120 | 1266689.560 | 475929.660 |
| 043 | 1271073.582 | 476291.356 | 121 | 1266708.840 | 475833.900 |
| 044 | 1271066.990 | 476290.050 | 122 | 1266638.858 | 475827.882 |
| 045 | 1270938.960 | 475789.360 | 123 | 1266724.060 | 475761.717 |
| 046 | 1271837.887 | 475557.631 | 124 | 1266726.346 | 475745.378 |
| 047 | 1272318.817 | 475448.784 | 125 | 1266734.477 | 475741.900 |
| 048 | 1272332.092 | 475459.752 | 126 | 1266737.148 | 475719.025 |
| 049 | 1272374.627 | 475547.821 | 127 | 1266744.588 | 475693.929 |
| 050 | 1270962.070 | 475901.220 | 128 | 1266767.319 | 475660.254 |
| 051 | 1270758.022 | 475917.619 | 129 | 1266781.627 | 475661.032 |
| 052 | 1270667.500 | 475930.106 | 130 | 1266759.589 | 475634.139 |
| 053 | 1270664.489 | 475838.608 | 131 | 1266779.790 | 475632.190 |
| 054 | 1270928.240 | 475785.950 | 132 | 1266761.540 | 475603.070 |
| 055 | 1271063.880 | 476290.080 | 133 | 1266652.590 | 475591.280 |
| 056 | 1270829.111 | 476256.990 | 134 | 1266652.360 | 475486.730 |
| 057 | 1270809.075 | 476144.347 | 135 | 1266770.922 | 475454.607 |
| 058 | 1270790.037 | 476117.375 | 136 | 1266775.895 | 475455.123 |
| 059 | 1270600.850 | 476088.980 | 137 | 1266813.8[illegible] | 475459.067 |
| 060 | 1270627.995 | 476230.220 | 138 | 1266815.591 | 475441.537 |
| 061 | 1270674.609 | 476216.510 | 139 | 1266942.182 | 475464.015 |
| 062 | 1270698.030 | 476341.899 | 140 | 1267069.890 | 475556.720 |
| 063 | 1270564.758 | 476390.504 | 141 | 1267202.180 | 475688.340 |
| 064 | 1270527.490 | 476411.620 | 142 | 1267255.080 | 475887.550 |
| 065 | 1270519.969 | 476386.330 | 143 | 1267312.070 | 475965.790 |
| 066 | 1270383.241 | 476399.027 | 144 | 1267405.580 | 475980.820 |
| 067 | 1270237.290 | 476369.638 | 145 | 1267476.160 | 475979.800 |
| 068 | 1270036.709 | 476333.542 | 146 | 1267463.767 | 475999.365 |
| 069 | 1270005.095 | 476455.028 | 147 | 1267455.714 | 476026.425 |
| 070 | 1269965.892 | 476579.286 | 148 | 1267446.920 | 476110.550 |
| 071 | 1269922.198 | 476705.077 | 149 | 1267536.610 | 476131.260 |
| 072 | 1269940.666 | 476839.343 | 150 | 1267535.440 | 476148.770 |
| 073 | 1269869.532 | 476861.977 | 151 | 1267565.990 | 476154.040 |
| 074 | 1269682.524 | 476944.213 | 152 | 1267575.630 | 476281.510 |
| 075 | 1269547.041 | 476869.966 | 153 | 1267608.467 | 476281.139 |
| 076 | 1269306.240 | 476810.780 | 154 | 1267623.242 | 476329.260 |
| 077 | 1269309.410 | 476742.700 | 155 | 1267650.175 | 476333.729 |
| 078 | 1269221.050 | 476072.410 | 156 | 1267695.810 | 476336.290 |

ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៦

លឹម វ៉ាន់

បានពិនិត្យត្រឹមត្រូវ

ភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៦

ប្រធាននាយកដ្ឋានបច្ចេកទេស

ភ្នំពេញ ថ្ងៃទី 24 ខែ មីនា ឆ្នាំ ២០០៦

ប្រធានក្រុមវាស់វែង